# អង្គការសមត្ថភាពខ្ញុំ (SKO)

# គោលនយោបាយស្តីពីកិច្ចការពារកុមារ
# (CPP)

កាលបរិច្ឆេទចូលជាធរមាន ០១/០១/២០១៥

កាលបិរច្ឆេទសម្រាប់ពិនិត្យឡើងវិញ[1] ០១/០១/២០២០

## ១. សេចក្តីថ្លែងអំពីគោលនយោបាយ

អង្គការសមត្ថភាពខ្ញុំទទួលស្គាល់ថា កុមារ គឺជាក្រុមមួយ ក្នុងចំណោមក្រុមដែលងាយរងគ្រោះជាងគេ ក្នុងសង្គម ហើយកុមារទាំងអស់មានសិទ្ធិទទួលបានសុវត្ថិភាព និងកិច្ចការពារ។ អង្គការសមត្ថភាពខ្ញុំ ទទួលស្គាល់ថា ការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ គឺជាការទទួលខុសត្រូវរួម។

អង្គការសមត្ថភាពខ្ញុំ ប្តេជ្ញាផ្តល់ការការពារដល់កុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពាន ដោយមិនគិតពីសញ្ជាតិ វប្បធម៌ ជាតិពន្ធុ យេនឌ័រ ជំនឿសាសនា ឬនយោបាយ ស្ថានភាពសង្គម-សេដ្ឋកិច្ច ប្រវត្តិគ្រួសារ ឬប្រវត្តិប្រព្រឹត្តបទល្មើស ឬសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត។

អង្គការសមត្ថភាពខ្ញុំ ប្តេជ្ញាបង្កើតនូវបរិយាកាសប្រកបដោយសុវត្ថិភាពសម្រាប់កុមារទាំងអស់ ដែលអង្គការនេះមានទំនាក់ទំនងជាមួយ តាមរយៈការអនុវត្តសកម្មភាពដែលធានានូវសុវត្ថិភាពកុមារ នៅក្នុងក្របខ័ណ្ឌនៃវប្បធម៌ កម្មវិធី និងសកម្មភាព គោលនយោបាយ និងនីតិវិធីរបស់អង្គការនេះ។ ការអនុវត្តទាំងនេះ ត្រូវតែយល់ និងអនុវត្ត នៅគ្រប់កម្រិតទាំងអស់។

អង្គការសមត្ថភាពខ្ញុំ ប្តេជ្ញាធានាថា អង្គការនេះ ក៏ដូចជាអ្នកដែលមានទំនាក់ទំនងជាមួយនឹងកុមារ ពាក់ព័ន្ធជាមួយនឹងសកម្មភាព និងកម្មវិធីនានារបស់អង្គការសមត្ថភាពខ្ញុំ មានកាតព្វកិច្ចគោរពតាមច្បាប់ជាតិ ដែលពាក់ព័ន្ធជាមួយនឹងកិច្ចការពារកុមារ។

អង្គការសមត្ថភាពខ្ញុំ ប្តេជ្ញាអនុវត្តទៅតាមស្តង់ដា ដែលត្រូវបានដាក់ចេញនៅក្នុងអនុសញ្ញាអន្តរជាតិ ពាក់ព័ន្ធជាមួយនឹងសិទ្ធិកុមារ និងកិច្ចការពារកុមារ។

## ២. គោលបំណង

គោលនយោបាយនេះ មានគោលបំណងការពារកុមារពីរាល់ទម្រង់ទាំងអស់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ច នៅក្នុងគ្រប់សកម្មភាព និងកម្មវិធីទាំងអស់របស់អង្គការសមត្ថភាពខ្ញុំ។

គោលនយោបាយនេះរៀបរាប់ពីចំណុចខាងក្រោមរបស់អង្គការសមត្ថភាពខ្ញុំ

- វិសាលភាព និងការទទួលខុសត្រូវ ដើម្បីការពារកុមារពីការរំលោភបំពាន
- ដំណើរការនៃការជ្រើសរើស និងពិនិត្យលើសាវតារ

[1] សូមមើលផ្នែក ៤.៧ នៃគោលនយោបាយនេះ

- ក្រមសីលធម៌
- នីតិវិធីសម្រាប់រាយការណ៍
- ការគ្រប់គ្រងហានិភ័យ និង
- និយមន័យវាក្យស័ព្ទ ដែលប្រើនៅក្នុងគោលនយោបាយនេះ (ឧ. "ការរំលោភបំពានកុមារ" ជាដើម)

**៣. វិសាលភាព**

គោលនយោបាយនេះអនុវត្តចំពោះ ៖

- សមាជិករបស់ក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការសមត្ថភាពខ្ញុំ
- អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ) ដែលផ្តល់សេវា ឬធ្វើការងារជាមួយនឹងអង្គការសមត្ថភាពខ្ញុំ

**៤. ការអនុវត្ត**

**៤.១. ការជ្រើសរើស និងពិនិត្យលើសាវតារ ដើម្បីធានាសុវត្ថិភាពកុមារ**

អង្គការសមត្ថភាពខ្ញុំប្រើប្រាស់ការជ្រើសរើស និងពិនិត្យលើសាវតារ ដើម្បីធានាសុវត្ថិភាពកុមារ[2] សម្រាប់ ៖

- សមាជិករបស់ក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការសមត្ថភាពខ្ញុំ
- អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ) ដែលផ្តល់សេវា ឬធ្វើការងារជាមួយនឹងអង្គការសមត្ថភាពខ្ញុំ

អ្នកដែលស្ថិតនៅក្នុងប្រភេទទាំងនេះ នឹងទទួលបានឯកសារគោលនយោបាយនេះ ទទួលបានការពន្យល់ដោយសង្ខេបពីគោលនយោបាយនេះ ជាផ្នែកមួយនៃការតម្រង់ទិស ឬការណែនាំដំបូង ហើយពួកគេត្រូវយល់ពីលក្ខខណ្ឌនានា នៃគោលនយោបាយនេះ។

**៤.២. ស្តង់ដានៃការប្រតិបត្តិការ និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ**

អង្គការសមត្ថភាពខ្ញុំ ផ្តល់ការណែនាំអំពីរបៀបកាត់បន្ថយហានិភ័យចំពោះកុមារ។ អង្គការនេះបានដាក់ចេញនូវស្តង់ដាឥរិយាបថ ដែលត្រូវគោរពតាមនៅគ្រប់ពេលទាំងអស់ នៅពេលដែលអ្នកណាម្នាក់ក្នុងអង្គការមានទំនាក់ទំនង ឬធ្វើការងារជាមួយកុមារ។ ស្តង់ដាទាំងនេះត្រូវបានដាក់ចេញនៅក្នុងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ។

សមាជិករបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការសមត្ថភាពខ្ញុំ អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ) ដែលផ្តល់សេវាដល់អង្គការសមត្ថភាពខ្ញុំ ឬធ្វើការងារជាមួយអង្គការសមត្ថភាពខ្ញុំ និងភ្ញៀវ ដែលមកកាន់អង្គការសមត្ថភាពខ្ញុំ ដែលមានទំនាក់ទំនង ឬធ្វើការងារជាមួយកុមារ ត្រូវបានផ្តល់ចុះហត្ថលេខា និងត្រូវគោរពតាមក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ។

---

[2] សូមមើលឧបសម្ព័ន្ធទី ១ ៖ ការជ្រើសរើស ដែលធានាបាននូវសុវត្ថិភាពកុមារ

អង្គការសមត្ថភាពខ្ញុំ ត្រូវទុកក្រមសីលធម៌ ដែលចុះហត្ថលេខាដោយមនុស្សម្នាក់ៗមួយច្បាប់ និងរក្សាបញ្ជីឈ្មោះអ្នកដែលបានទទួលក្រមសីលធម៌នេះ បានចុះហត្ថលេខាលើក្រមសីលធម៌នេះ និងបានទទួលការបណ្តុះបណ្តាលអំពីកាតព្វកិច្ច នៅក្នុងក្រមសីលធម៌នេះ។

**៤.៣. ការបណ្តុះបណ្តាល និងការបង្កើនការយល់ដឹង**

គ្រប់សមាជិកទាំងអស់របស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការសមត្ថភាពខ្ញុំ ដែលមានទំនាក់ទំនង ឬដែលកំពុង ឬប្រហែលជាកំពុងធ្វើការងារជាមួយកុមារ ត្រូវចូលរួមនៅក្នុងការបណ្តុះបណ្តាលបង្កើនការយល់ដឹងអំពីកិច្ចការពារកុមារឱ្យបានជាប្រចាំ។

**៤.៤. នីតិវិធី សម្រាប់រាយការណ៍ពីការរំលោភបំពានកុមារ**

របាយការណ៍អំពីការរំលោភបំពានកុមារ អាចមានដាក់បញ្ចូលនូវការបង្ហាញ ការព្រួយបារម្ភ ឬការចោទប្រកាន់ ដែលធ្វើឡើងដោយកុមារណាម្នាក់ ឬដោយមនុស្សផ្សេងទៀត ពីការរំលោភបំពានកុមារ ឬការបំពានក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ។[3]

អង្គការសមត្ថភាពខ្ញុំ ប្តេជ្ញាធានាថា សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ក៏ដូចជាសេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ពួកគេ នៅតែទទួលបានការយកចិត្តទុកដាក់ជាងគេ នៅគ្រប់ពេលវេលាទាំងអស់។ អង្គការសមត្ថភាពខ្ញុំនឹង ៖

- ខិតខំគ្រប់បែបយ៉ាង ដើម្បីការពារសិទ្ធិ និងសុវត្ថិភាពរបស់កុមារ នៅក្នុងកំឡុងពេល ដែលមានការស៊ើបអង្កេតលើករណីមានការរាយការណ៍ពីការរំលោភបំពានលើកុមារ
- យកចិត្តទុកដាក់ចំពោះករណីរាយការណ៍ពីការរំលោភបំពានកុមារ និងធានាយ៉ាងណាឱ្យគ្រប់ភាគីទាំងអស់ទទួល បានការប្រតិបត្តិដោយស្មើភាពគ្នា
- ដោះស្រាយករណីរំលោភបំពានកុមារ ដែលត្រូវបានរាយការណ៍ ដោយរក្សាការសំងាត់[4] ប្រកបដោយភាពយុត្តិធម៌ និងទាន់ពេលវេលា
- ធានាឱ្យមានការការពារប្រយោជន៍របស់អ្នកដែលធ្វើការរាយការណ៍ ប្រកបដោយសុច្ឆន្ទៈ។ [រាល់ការរាយការណ៍ទាំងអស់ ដែលធ្វើឡើងដោយសុច្ឆន្ទៈ នឹងត្រូវបានចាត់ទុកថាជាការរាយការណ៍ ដែលធ្វើឡើង ដើម្បីប្រយោជន៍បំផុតរបស់កុមារ ដោយមិនគិតពីលទ្ធផលនៃការស៊ើបអង្កេតឡើយ។]

បុគ្គលិក អ្នកស័គ្រចិត្ត ឬបុគ្គលិក ដែលមានចេតនារាយការណ៍ខុស ឬរាយការណ៍ក្នុងលក្ខណៈមួលបង្កាច់ អាចទទួលរងការដាក់វិធានការវិន័យ។

---

[3] តារាងលំហូរបង្ហាញពីនីតិវិធីរាយការណ៍ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៤

អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ) ដែលមានចេតនារាយការណ៍ខុស ឬរាយការណ៍ក្នុងលក្ខណៈមួលបង្កាច់ អាចរងការផ្តាច់កិច្ចសន្យា។

**៤.៤.១ ការរាយការណ៍**

ប្រសិនបើបុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ) ឬសមាជិកណាម្នាក់បានដឹងពី ៖

- ការរំលោភបំពានលើកុមារ តាមរយៈការបង្ហាញព័ត៌មានពីកុមារ ភាគីទីបី និង/ឬការសង្កេតឃើញដោយផ្ទាល់ និង/ឬ
- ការបំពាន ឬលទ្ធភាពអាចមានការបំពានលើក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ

ពួកគេត្រូវរាយការណ៍ពីករណីនេះជាបន្ទាន់ ដល់មន្ត្រីការពារកុមារ (CPO) របស់អង្គការសមត្ថភាពខ្ញុំ។

អ្នកផ្សេងទៀត ដូចជា អ្នកនៅក្នុងសហគមន៍ ឬភ្ញៀវ ជាដើម ក៏អាចរាយការណ៍ពីការរំលោភបំពានលើកុមារ ទៅកាន់មន្ត្រីការពារកុមារ (CPO) របស់អង្គការសមត្ថភាពខ្ញុំផងដែរ។

**៤.៤.២ ការចាត់វិធានការលើការរាយការណ៍ពីករណីរំលោភបំពានលើកុមារ**

គ្រប់សមាជិកទាំងអស់របស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការសមត្ថភាពខ្ញុំ ដែលដឹងពីការរាយការណ៍អ្វីមួយ ត្រូវ ៖

- ពិភាក្សាពីការព្រួយបារម្ភនានា ជាមួយនឹងនាយកប្រតិបត្តិរបស់អង្គការសមត្ថភាពខ្ញុំ និង
- បំពេញសន្លឹករាយការណ៍ពីឧប្បទ្ទវហេតុ[5] ដោយត្រូវរៀបរាប់លំអិតពីអ្នកដែលរាយការណ៍ និង/ឬសាក្សី ឬអ្នកដែលអាចមានព័ត៌មានពាក់ព័ន្ធ

មន្ត្រីការពារកុមារ របស់អង្គការសមត្ថភាពខ្ញុំ ត្រូវពិភាក្សាពីការព្រួយបារម្ភនេះ ជាមួយនឹងអ្នកដែលធ្វើការចោទប្រកាន់ ឬសាក្សីផ្សេងទៀត ដើម្បីប្រមូលព័ត៌មានបន្ថែម ក្នុងគោលបំណងអាចមានព័ត៌មានគ្រប់គ្រាន់ សម្រាប់ ៖

- កំណត់ពីហានិភ័យដែលអាចកើតមានភ្លាមៗ និងដែលអាចកើតមានឡើងចំពោះកុមារ ឬមនុស្សវ័យក្មេង
- រៀបចំ និងអនុវត្តផែនការសកម្មភាពមួយ ដើម្បីធានាសុវត្ថិភាពរបស់កុមារ

ផែនការសកម្មភាពនេះត្រូវមានដាក់បញ្ចូលចំណុចខាងក្រោម ប៉ុន្តែមិនមែនកំហិតត្រឹមតែចំណុចទាំងនេះនោះទេ ៖

---

[5]សូមមើលឧបសម្ព័ន្ធទី ៣ - សន្លឹករាយការណ៍ពីឧប្បទ្ទវហេតុ

- រាយការណ៍ពីបញ្ហានេះទៅកាន់នគរបាលមូលដ្ឋាន និង/ឬអាជ្ញាធរខាងការពារកុមារ និង/ឬ
- ធានាឱ្យមានការបញ្ជូន និងការផ្តល់ការគាំទ្រដល់កុមារ និង/ឬ
- ដោះស្រាយបញ្ហានេះខាងក្នុងអង្គការ ទៅតាមដំណើរការរបស់អង្គការ ប្រសិនបើវាមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬ
- មិនចាត់វិធានការបន្ថែមទៀតឡើយ

**៤.៥ ការគ្រប់គ្រងហានិភ័យ**

អង្គការសមត្ថភាពខ្ញុំ នឹងកំណត់ពីហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ នៅក្នុងគ្រប់សកម្មភាពទាំងអស់ (ដូចជា ក្នុងកម្មវិធី គម្រោង និងមុខតំណែងនានា) និងអនុម័តយុទ្ធសាស្ត្រ សម្រាប់ធ្វើការគ្រប់គ្រងហានិភ័យដែលបានដឹង។ ការវាយតម្លៃលើហានិភ័យត្រូវ ៖

- កំណត់ពីហានិភ័យ
- បញ្ជាក់ឱ្យបានច្បាស់ពីសកម្មភាពទាំងឡាយ ដែលមានហានិភ័យខ្ពស់ និង
- ចងក្រងទុកជាឯកសារនូវជំហាននានា ដែលត្រូវអនុវត្ត ដើម្បីកាត់បន្ថយ ឬលុបបំបាត់ហានិភ័យ

គេត្រូវធ្វើការវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពហានិភ័យ នៅក្នុងរយៈពេលទាំងមូលនៃសកម្មភាព ដែលត្រូវបានវាយតម្លៃ។

អង្គការសមត្ថភាពខ្ញុំនឹងមិនអនុញ្ញាតឱ្យអ្នកម្នាក់ ធ្វើការងារ ឬទំនាក់ទំនងជាមួយកុមារឡើយ ប្រសិនបើពួកគេបង្កជាហានិភ័យចំពោះសុវត្ថិភាព ឬសុខុមាលភាពរបស់កុមារនោះ។

**៤.៦. ប្បញ្ញត្តិក្នុងកិច្ចសន្យាការងារ**

កិច្ចសន្យាការងារនីមួយៗ ត្រូវមានដាក់បញ្ចូលសិទ្ធិឱ្យអង្គការសមត្ថភាពខ្ញុំបណ្តេញចេញពីការងារ ព្យួរការងារ ឬផ្ទេរទៅកាន់ភារកិច្ចផ្សេងទៀត នូវបុគ្គលិកណាម្នាក់ ដែលបំពានក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ។

**៤.៧. ការពិនិត្យតាមដាន និងការពិនិត្យឡើងវិញលើគោលនយោបាយ**

ការពិនិត្យតាមដានលើការអនុវត្តគោលនយោបាយ គឺជាការទទួលខុសត្រូវរបស់បុគ្គលិកគ្រប់រូប ជាពិសេសមន្ត្រីការពារកុមារ របស់អង្គការសមត្ថភាពខ្ញុំ។

គោលនយោបាយនេះត្រូវពិនិត្យឡើងវិញ រៀងរាល់ ៥ ឆ្នាំម្តង និងឆាប់ជាងនេះ ប្រសិនបើមានការផ្លាស់ប្តូរស្តង់ដាជាតិ និង/ឬអន្តរជាតិនានា ដើម្បីឱ្យគោលនយោបាយនេះនៅតែមានបច្ចុប្បន្នភាព មានប្រសិទ្ធភាព និងមានភាពសមស្រប។

## ៥. និយមន័យ

| | |
|---|---|
| “មនុស្សពេញវ័យ” | មនុស្ស ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ |
| “កុមារ” | មនុស្ស ដែលមានអាយុក្រោម ១៨ ឆ្នាំ |
| “ការរំលោភបំពានលើកុមារ” | ករណីមួយ ឬច្រើន ក្នុងចំណោមករណីខាងក្រោម ៖<br>• ការរំលោភបំពានផ្លូវកាយ<br>• ការរំលោភបំពានផ្លូវភេទ<br>• ការរំលោភបំពានផ្លូវចិត្ត<br>• ការមិនយកចិត្តទុកដាក់<br>• ការកេងប្រវ័ញ្ច |
| “សម្ភារដែលរំលោភបំពានលើកុមារ” | សម្ភារ ដែលបង្ហាញ (ដោយផ្ទាល់ ឬដោយប្រយោល) កុមារថាជាជនរងគ្រោះ ដោយសារការធ្វើទារុណកម្ម អំពើឃោរឃៅ ឬការរំលោភបំពានផ្លូវកាយ |
| “ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ” | ករណីមួយ ឬច្រើន ក្នុងចំណោមករណីខាងក្រោម ៖<br>• ការប្រព្រឹត្ត ឬការបង្ខំឱ្យជនម្នាក់ទៀតឱ្យប្រព្រឹត្តអំពើអ្វីមួយ ឬច្រើន ដែលជាការរំលោភបំពានលើកុមារ<br>• ការកាន់កាប់ ការគ្រប់គ្រង ការផលិត ការចែកចាយ ការទទួល ឬការបញ្ជូនសម្ភារ ដែលកេងប្រវ័ញ្ចលើកុមារ<br>• ការប្រព្រឹត្ត ឬការបង្ខំឱ្យជនម្នាក់ទៀតឱ្យប្រព្រឹត្តអំពើអ្វីមួយ ឬច្រើន ដែលជាការសំអិតសំអាងកុមារ ឬការសំអិតសំអាងកុមារតាមប្រព័ន្ធអនឡាញ |
| “សម្ភារកេងប្រវ័ញ្ចញលើកុមារ” | សម្ភារនានា ដោយមិនគិតពីទម្រង់របស់វា ដែលជាសម្ភារបង្ហាញពីការរំលោភបំពានលើកុមារ ឬសម្ភារបង្ហាញពីរូបអាសអាភាសរបស់កុមារ |
| “រូបអាសអាភាសកុមារ” | ការបង្ហាញនានា ទោះដោយមធ្យោបាយអ្វីក៏ដោយ អំពីកុមារម្នាក់ ដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ដោយពិតក្តី ឬជាការធ្វើត្រាប់ក្តី ឬការបង្ហាញពីផ្នែកផ្លូវភេទរបស់កុមារ ដើម្បីគោលបំណងសំខាន់ ដែលពាក់ព័ន្ធជាមួយនឹងផ្លូវភេទ |
| “សម្ភារបង្ហាញពីរូបអាសអាភាសកុមារ” | សម្ភារ ដែលបង្ហាញពីមនុស្សម្នាក់ ឬគឺជារូបរបស់មនុស្សម្នាក់ ដែលមានអាយុ ឬហាក់បីដូចជាមានអាយុក្រោម ១៨ ឆ្នាំ និងចូលរួម ឬហាក់បីដូចជាចូលរួម នៅ |

| | |
|---|---|
| | ក្នុងកាយវិការផ្លូវភេទ ឬសកម្មភាពផ្លូវភេទ ឬនៅក្នុងករណីដែលមានវត្ថុមានរបស់អ្នក ដែលចូលរួមក្នុងកាយវិការផ្លូវភេទ ឬសកម្មភាពផ្លូវភេទ ហើយធ្វើ តាមបែបផែនដែលមនុស្សធម្មតាម្នាក់ចាត់ទុកថាជាការប្រមាថមាក់ងាយ នៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ |
| "ការការពារកុមារ" | សកម្មភាព ឬគំនិតផ្តួចផ្តើមអ្វីមួយ ដែលមានគោលបំណងទប់ស្កាត់ ឬឆ្លើយតបចំពោះឧប្បទ្ទវហេតុរំលោភបំពានលើកុមារជាក់លាក់ |
| "ការមានទំនាក់ទំនងជាមួយកុមារ" | ការធ្វើការងារ ឬការចូលរួមនៅក្នុងសកម្មភាពមួយ ឬនៅក្នុងមុខតំណែងអ្វីមួយ ដែលមានពាក់ព័ន្ធជាមួយនឹងការមានទំនាក់ទំនងជាមួយកុមារ អាចជាការស្ថិតក្រោមពិពណ៌នាការងារ ឬដោយសារតែលក្ខណៈនៃបរិយាកាសការងារ |
| "អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ)" | បុគ្គល ឬអង្គការស្ថាប័ន ដែលធ្វើការងាររួមគ្នាជាមួយ ឬផ្តល់សេវាដល់អង្គការសមត្ថភាពខ្ញុំ ដូចជា ទីប្រឹក្សា និងអង្គការដៃគូ ជាដើម |
| "ការរំលោភបំពានផ្លូវចិត្ត" | ការប្រើពាក្យសម្តី ឬការប្រព្រឹត្តទង្វើមិនសមស្របរបស់មាតាបិតា ឬអាណាព្យាបាលចំពោះកូន ឬនិន្នាការនៃការខកខាន ក្នុងរយៈពេលមួយ ក្នុងការផ្តល់ឱ្យកូននូវការទំនុកបម្រុងពុំមានលក្ខណៈរូបវ័ន្ត និងការគាំទ្រផ្លូវចិត្តឱ្យបានគ្រប់គ្រាន់ ដែលអាចធ្វើឱ្យខូចខាតដល់ការផ្តល់តម្លៃដល់ខ្លួនឯង និងសមត្ថភាពសង្គមរបស់កូន |
| "ការសំអិតសំអាងកុមារ" | ឥរិយាបថ ដែលធ្វើឱ្យជនល្មើសម្នាក់ងាយស្រួលរកកុមារ ដើម្បីធ្វើសកម្មភាពផ្លូវភេទ (ដូចជា ការសំអិតសំអាងកុមារតាមអនឡាញ ជាដើម) |
| "ការសំអិតសំអាងកុមារ តាមអនឡាញ" | សកម្មភាពបញ្ជូនសារអេឡិចត្រូនិច ដែលមានខ្លឹមសារមិនសមរម្យដល់អ្នកទទួលសារ ដែលអ្នកផ្ញើរជឿថាមានអាយុក្រោម ១៦ ឆ្នាំ ក្នុងគោលបំណងឱ្យអ្នកទទួលសារចូលរួម ឬរងសកម្មភាពផ្លូវភេទជាមួយមនុស្សម្នាក់ផ្សេងទៀត រួមទាំង ប៉ុន្តែចាំបាច់ជាអ្នកផ្ញើនោះ |
| "ការមិនអើពើ" | ការខកខានរបស់មាតាបិតា ឬអាណាព្យាបាល ក្នុងការផ្តល់ឱ្យកូន (នៅក្នុងករណីដែលពួកគេមានតួនាទីធ្វើបែបនេះ) ក្រោមលក្ខខណ្ឌ ដែលអាចទទួលយកបានតាមវប្បធម៌ ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ ចំពោះការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត និងសុខុមាលភាពរបស់ពួកគេ |

| | |
|---|---|
| “ការរំលោភបំពានផ្លូវកាយ” | ការប្រើប្រាស់កម្លាំងកាយលើកុមារណាម្នាក់ ដែលនាំឱ្យមានគ្រោះថ្នាក់ចំពោះកុមារនោះ។ ឥរិយាបថរំលោភបំពានផ្លូវកាយ អាចមានដូចជា ការច្រាន ក្តិច វាយដំ ទាត់ ខាំ ដុត ចាប់រលាក់ គាប់ រឹតក និងដាក់ថ្នាំបំពុល |
| “ការរំលោភបំពានផ្លូវភេទ” | ការប្រើកុមារ សម្រាប់បំពេញចំណង់ផ្លូវភេទរបស់មនុស្សពេញវ័យ ឬកុមារ ឬក្មេងជំទង់ ដែលមានអាយុច្រើនឆ្ងាយជាង។ ឥរិយាបថរំលោភបំពានផ្លូវភេទ អាចរួមមានការស្ទាបអង្អែលប្រដាប់ភេទ ការសម្រេចបំណងផ្លូវភេទដោយខ្លួនឯង ការរួមភេទតាមមាត់ ការស៊កលិង្គ ម្រាមដៃ ឬរបស់ផ្សេងទៀត តាមយោនី ឬរន្ធគូថ ការស្ទាបអង្អែលដោះ ការលួចមើលគេរួមភេទ ការបង្ហាញកេរ្តិ៍ភេទ និងការឱ្យកុមារមើលរូបអាសអាភាស ឬឱ្យកុមារចូលរួមក្នុងការការផលិតរូបអាសអាភាស។ |

ឯកសារភ្ជាប់

**ឧបសម្ព័ន្ធទី ១ ៖ ការជ្រើសរើស ដែលធានាបាននូវសុវត្ថិភាពកុមារ**

**ឧបសម្ព័ន្ធទី ២ ៖ ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ**

**ឧបសម្ព័ន្ធទី ៣ ៖ សន្លឹករាយការណ៍ពីឧប្បទ្ទវហេតុ**

**ឧបសម្ព័ន្ធទី ៤ ៖ នីតិវិធីសម្រាប់រាយការណ៍**

**ឧបសម្ព័ន្ធទី ៥ ៖ ការគ្រប់គ្រងហានិភ័យ**

**ឧបសម្ព័ន្ធទី ៦ ៖ កិច្ចព្រមព្រៀងទទួលយកគោលនយោបាយស្តីពីកិច្ចការពារកុមារ**

**ឧបសម្ព័ន្ធទី ១ ៖ ការជ្រើសរើស ដែលធានាបាននូវសុវត្ថិភាពកុមារ**

សម្រាប់រាល់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ បុគ្គលិក អ្នកស័គ្រចិត្ត និងអ្នកទទួលកិច្ចសន្យា (អ្នកម៉ៅការ) ដែលនឹងធ្វើការងារជាមួយកុមារ ឬដែលអាចមានទំនាក់ទំនងជាមួយកុមារ ត្រូវមានការអនុវត្តដំណើរការខាងក្រោម ៖

ការពិនិត្យសារតារ

១. សំណួរសម្ភាសអំពីឥរិយាបថចំគោលដៅ ដែលមានលក្ខណៈជាក់លាក់តាមមុខតំណែង ដែលពាក់ព័ន្ធនឹងការធ្វើការងារ ឬការមានទំនាក់ទំនងជាមួយកុមារ នឹងត្រូវដាក់បញ្ចូលទៅក្នុងកាលវិភាគសម្ភាស

២. បេក្ខជនត្រូវបានស្នើឱ្យបង្ហាញ ហើយត្រូវបង្ហាញថាតើពួកគេធ្លាប់ត្រូវបានចោទប្រកាន់ពីបទរំលោភបំពាន ឬកេងប្រវ័ញ្ចលើកុមារដែរឬទេ

៣. អ្នកដែលផ្តល់ការធានាដល់បេក្ខជន ដែលចាត់ទុកថាជាបេក្ខជនអាទិភាព ជានិច្ចកាល ត្រូវបានសួរថាតើពួកគេមានការព្រួយបារម្ភអ្វីអំពីបេក្ខជននេះ (ឬថាតើមានការដាក់ពាក្យបណ្តឹងអំពីបេក្ខជននេះ) ពាក់ព័ន្ធនឹងការធ្វើការងារ ឬការមានទំនាក់ទំនងជាមួយកុមារដែរឬទេ

**[អាចថា]**[6]

- បេក្ខជនជាអាទិភាព ត្រូវដាក់លិខិតថ្កោលទោស[7] ដូចរៀបរាប់ខាងក្រោម ពាក់ព័ន្ធជាមួយនឹងបទល្មើស ទាក់ទិននឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចលើកុមារគ្រប់រូបភាពទាំងអស់
- លិខិតថ្កោលទោសជាទីពេញចិត្ត គឺជាបុរេលក្ខខណ្ឌសម្រាប់ការតែងតាំងបេក្ខជនអាទិភាពនេះជានិយោជិត ឬជាអ្នកស្ម័គ្រចិត្ត

**[ឬ]**

- បេក្ខជនជាអាទិភាពនេះ នឹងត្រូវបានស្នើឱ្យចុះហត្ថលេខាលើសេចក្តីប្រកាសចងកាតព្វកិច្ចតាមផ្លូវច្បាប់ ចំពោះលិខិតថ្កោលទោស ពាក់ព័ន្ធនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចលើកុមារគ្រប់រូបភាពទាំងអស់
- សេចក្តីប្រកាសជាទីពេញចិត្ត គឺជាបុរេលក្ខខណ្ឌនៃការតែងតាំងបេក្ខជនជាអាទិភាពនេះជា និយោជិត ឬជាអ្នកស្ម័គ្រចិត្ត

---

[6] ត្រូវប្រើលិខិតថ្កោលទោសផ្លូវការ លើកលែងតែក្នុងករណីពុំមាន ឬមិនអាចរកបាននូវលិខិតថ្កោលទោសដែលអាចជឿទុកចិត្តបាន

[7] បញ្ចូលតែប្រសិនបើមានការពិនិត្យលើប្រវត្តិប្រព្រឹត្តបទល្មើស នៅក្នុងប្រទេស និងក្នុងកម្រិតដែលពាក់ព័ន្ធប៉ុណ្ណោះ

**ការពិនិត្យលើលិខិតថ្កោលទោស**

ការពិនិត្យលើលិខិតថ្កោលទោសសម្រាប់បេក្ខជនណាម្នាក់ ត្រូវគ្របដណ្តប់លើ ៖

- ប្រទេសនីមួយៗ ដែលបេក្ខជននេះបានរស់នៅ ចាប់ពី ១២ ខែ ឡើងទៅ នៅក្នុងរយៈពេល ៥ ឆ្នាំ មុនកាលបរិច្ឆេទនៃការពិនិត្យឡើងវិញនេះ និង
- ប្រទេសដែលផ្តល់សញ្ជាតិដល់បេក្ខជននេះ

អាចពុំមានការពិនិត្យលើលិខិតថ្កោលទោសឡើយ លើកលែងតែក្នុងករណីដែលបេក្ខជននេះយល់ព្រមឱ្យមានការទទួលបានលិខិតថ្កោលទោសនេះ។ ប្រសិនបើពុំមានការយល់ព្រមបែបនេះទេ បេក្ខជននេះមិនអាចទទួលបានមុខតំណែង នៅក្នុងអង្គការនេះឡើយ។

បេក្ខជនត្រូវទទួលបានព័ត៌មានអំពី ៖

- លិខិតបញ្ជាក់ទាំងឡាយ ដែលបានពីការពិនិត្យលើលិខិតថ្កោលទោស នឹងត្រូវប្រើប្រាស់ សម្រាប់ភ្ជាប់ទំនាក់ទំនងជាមួយនឹងការកំណត់ថាតើនឹងមានការផ្តល់មុខតំណែងដល់បេក្ខជនរូបនេះដែរឬទេ និង
- លិខិតបញ្ជាក់នេះ អាចបង្ហាញទៅដល់ទីភ្នាក់ងារផ្តល់មូលនិធិនានា (ដូចជា AusAID/USAID ជាដើម)

ត្រូវមានការរក្សាឯកសារលំអិតអំពីការជ្រើសរើសបុគ្គលិក (រួមនឹងការឆ្លើយតបចំពោះសំណើឱ្យបង្ហាញពីការចោទប្រកាន់ពីបទរំលោភបំពានលើកុមារ យោបល់របស់អ្នកធានា និងលទ្ធផលនៃការពិនិត្យលើលិខិតថ្កោលទោស ឬដំណើរការដទៃទៀត)។

**ឧបសម្ព័ន្ធទី ២ ស្តង់ដាឥរិយាបថ - ក្រមសីលធម៌ស្តីពីកិច្ចការពារកុមាររបស់អង្គការសមត្ថភាពខ្ញុំ**

ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ អនុវត្តចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ បុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកទទួលបានកិច្ចសន្យា (អ្នកម៉ៅការ) និងភ្ញៀវ ដែលមានទំនាក់ទំនងជាមួយនឹងអង្គការសមត្ថភាពខ្ញុំ។

ក្រមសីលធម៌នេះកំណត់ពីស្តង់ដាឥរិយាបថ ដែលអង្គការសមត្ថភាពខ្ញុំរំពឹងចង់បាន ដើម្បីផ្តល់ការការពារដល់កុមារ។

ខ្ញុំយល់ថា ខណៈពេលកំពុងធ្វើការងារជាមួយ ឬចូលរួមក្នុងសកម្មភាពនានា ដែលទទួលបានថវិកាពីអង្គការសមត្ថភាពខ្ញុំ ខ្ញុំនឹង ៖

- ប្រតិបត្តិចំពោះកុមារប្រកបដោយការគោរព ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត សញ្ជាតិដើម ជាតិកំណើត ឬដើម្បីកំណើតសង្គម ទ្រព្យសម្បត្តិ ពិការភាព ស្ថានភាពពេលកំណើត ឬស្ថានភាពផ្សេងទៀត។
- មិនប្រើភាសា ឬឥរិយាបថចំពោះកុមារ ដែលមិនសមស្រប មានចរិតជាការបៀតបៀន ការរំលោភបំពាន ការបំផុសអារម្មណ៍ផ្លូវភេទ ការប្រមាថមើលងាយ ឬការមិនសមស្របផ្នែកវប្បធម៌។
- មិនឱ្យកុមារ (អាយុក្រោម ១៨ ឆ្នាំ) ណាម្នាក់ ចូលរួមនៅក្នុងសកម្មភាព ឬទង្វើផ្លូវភេទ រួមទាំងការបង់លុយសម្រាប់សេវា ឬទង្វើផ្លូវភេទផង។
- នៅក្នុងករណីដែលអាចធ្វើបាន ត្រូវមានមនុស្សពេញវ័យម្នាក់ទៀតមានវត្តមាន នៅពេលធ្វើការងារ ជិតកុមារ។
- មិនអញ្ជើញកុមារដែលគ្មានមនុស្សមកអមជាមួយ ចូលក្នុងផ្ទះរបស់ខ្ញុំ លើកលែងតែមានករណីមានការយល់ព្រមពីនាយក នៅក្នុងករណីមានអាសន្នខុសធម្មតា និងមិនអាចប្រមើលដឹងជាមុនបាន។
- មិនគេងជិតកុមារដែលគ្មានអ្នកឃុំគ្រង លុះត្រាតែចាំបាច់បំផុត ដែលក្នុងករណីបែបនេះ ខ្ញុំត្រូវមានការអនុញ្ញាតពីអ្នកគ្រប់គ្រងផ្ទាល់របស់ខ្ញុំ និងត្រូវធានាថាមានមនុស្សពេញវ័យម្នាក់ទៀតមានវត្តមានដែរ ប្រសិនបើអាចធ្វើបាន។
- ប្រើកុំព្យូទ័រ ទូរស័ព្ទដៃ ឬម៉ាស៊ីនថតវីដេអូ និងម៉ាស៊ីនថតឌីជីថលឱ្យបានសមស្រប និងមិនត្រូវកេងប្រវ័ញ្ច ឬបៀតបៀនកុមារ ឬចូលមើលខ្លឹមសារដែលកេងប្រវ័ញ្ចលើកុមារ តាមរយៈមធ្យោបាយនានា (សូមមើល "ការប្រើប្រាស់រូបភាពកុមារ សម្រាប់គោលបំណងពាក់ព័ន្ធនឹងការងារ" ខាងក្រោម)
- មិនប្រើការដាក់ទណ្ឌកម្មរាងកាយលើកុមារ។
- មិនជួលកុមារឱ្យធ្វើការងារផ្ទះ ឬការងារផ្សេងទៀត ដែលមិនសមស្រប ដោយសារតែអាយុ ឬដំណាក់កាលអភិវឌ្ឍរបស់ពួកគេ ដែលអាចរំខានដល់ពេលវេលារបស់ពួកគេ សម្រាប់ទទួលបានការអប់រំ និងធ្វើសកម្មភាពកម្សាន្ត ឬដែលធ្វើឱ្យពួកគេត្រូវទទួលរងរបួស។

- អនុលោមតាមរាល់ច្បាប់ក្នុងស្រុកពាក់ព័ន្ធទាំងអស់ ដូចជា ច្បាប់ការងារ ដែលពាក់ព័ន្ធនឹងពលកម្មកុមារ ជាដើម។
- រាយការណ៍ភ្លាមៗពីក្ដីបារម្ភ ឬការចោទប្រកាន់នានាអំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ ស្របតាមគោលនយោបាយស្ដីពីកិច្ចការពារកុមាររបស់អង្គការសមត្ថភាពខ្ញុំ។
- បង្ហាញជាបន្ទាន់ពីការចោទប្រកាន់ ការផ្ដន្ទាទោស និងលទ្ធផលនៃបទល្មើសអ្វីមួយទាក់ទិននឹងការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ ដែលបានកើតឡើងមុន ពេល ឬក្នុងកំឡុងពេល ដែលខ្ញុំធ្វើការងារពាក់ព័ន្ធនឹងអង្គការសមត្ថភាពខ្ញុំ។

**ការប្រើប្រាស់រូបភាពរបស់កុមារ សម្រាប់គោលបំណងពាក់ព័ន្ធនឹងការងារ**

នៅពេលថតរូប ឬថតវីដេអូ ឬប្រើប្រាស់រូបភាពរបស់កុមារ សម្រាប់គោលបំណងពាក់ព័ន្ធនឹងការងារ ខ្ញុំត្រូវ ៖

- វាយតម្លៃ និងខិតខំអនុវត្តតាមប្រពៃណី ឬការហាមឃាត់ក្នុងស្រុក ពាក់ព័ន្ធនឹងការផលិតរូបភាពផ្ទាល់ខ្លួន មុននឹងថតរូប ឬថតវីដេអូរបស់កុមារណាម្នាក់។
- ទទួលបានការយល់ព្រម ផ្អែកតាមព័ត៌មានត្រឹមត្រូវ (និងជាលាយលក្ខណ៍អក្សរ) ពីកុមារ និងមាតាបិតា ឬអាណាព្យាបាលរបស់កុមារ មុនពេលថតរូប ឬថតវីដេអូកុមារ។ ជាផ្នែកមួយនៃការសុំការអនុញ្ញាតនេះ ខ្ញុំត្រូវពន្យល់ពីរបៀបដែលរូបថត ឬវីដេអូនេះ នឹងត្រូវយកទៅប្រើប្រាស់។
- ធានាថា រូបថត វីដេអូ និងឌីវីឌី បង្ហាញពីកុមារប្រកបដោយសេចក្ដីថ្លៃថ្នូរ និងការគោរព មិនមែនប្រកបដោយភាពងាយរងគ្រោះ ឬចាញ់ប្រៀបគេនោះទេ។ កុមារគួរមានស្លៀកពាក់ឱ្យបានគ្រប់គ្រាន់ ហើយមិនត្រូវថតក្នុងកាយវិការ ដែលអាចមើលទៅថាជាការបំផុសអារម្មណ៍ផ្លូវភេទនោះទេ។
- ធានាថា រូបភាពនានា គឺជាតំណាងដោយស្មោះត្រង់ពីបរិបទ និងអង្គហេតុនានា។ និង
- ធានាថា ស្លាកសម្គាល់ឯកសារ ទិន្នន័យមេ ឬអត្ថបទពិពណ៌នា មិនបង្ហាញព័ត៌មានអត្តសញ្ញាណអំពីកុមារ នៅពេលបញ្ជូនរូបភាពក្នុងទម្រង់អេឡិចត្រូនិច ឬបោះពុម្ពផ្សាយរូបភាព ទោះជាក្នុងទម្រង់អ្វីក៏ដោយ។

ខ្ញុំយល់ថា ក្នុងនាមជាមនុស្សម្នាក់ ដែលមានទំនាក់ទំនងជាមួយនឹងអង្គការសមត្ថភាពខ្ញុំ ខ្ញុំមានកាតព្វកិច្ចប្រើប្រាស់សុភវិនិច្ឆ័យ និងចៀសវាងមិនធ្វើសកម្មភាព ឬឥរិយាបថ ដែលអាចចាត់ទុកថាជាការកេងប្រវ័ញ្ច និងការបៀតបៀនលើកុមារ។

ខ្ញុំទទួលស្គាល់ថា ខ្ញុំត្រូវបានគេផ្ដល់ឱ្យ និងបានអានគោលនយោបាយស្ដីពីកិច្ចការពារកុមារ ហើយការខកខានមិនបានអនុវត្តតាមក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារនេះ អាចនាំឱ្យមានការដាក់វិធានការវិន័យ វិធានការផ្លូវច្បាប់ ឬការស៊ើបអង្កេតបទព្រហ្មទណ្ឌ និងការផ្ដន្ទាទោស។

ហត្ថលេខា ៖ ________________________

កាលបរិច្ឆេទ ៖ ________________________

**ឧបសម្ព័ន្ធទី ៣ ៖ សន្លឹករាយការណ៍ពីឧប្បទ្ទវហេតុ**

សូមបំពេញទម្រង់នេះ ប្រសិនបើអ្នកជឿថា អាចមានករណីរំលោភបំពាន ឬកេងប្រវ័ញ្ចលើកុមារ ឬការបំពានក្រមសីលធម៌ស្តីពីកិច្ចការពារកុមារនេះកើតឡើង ឬកុមារណាម្នាក់កំពុងទទួលរងគ្រោះថ្នាក់។ រាល់បញ្ហា ពាក់ព័ន្ធនឹងកិច្ចការពារកុមារទាំងអស់ គួររាយការណ៍ភ្លាមៗ ទៅកាន់មន្ត្រីការពារកុមាររបស់អង្គការសមត្ថភាពខ្ញុំ។ ការរាយការណ៍នេះត្រូវរក្សាទុកជាការសំងាត់បំផុត។

| | |
|---|---|
| កាលបរិច្ឆេទនៃថ្ងៃនេះ ៖ | ____________________ |
| ពេលវេលានៃថ្ងៃនេះ ៖ | ____________________ |
| ទីកន្លែង/អាសយដ្ឋាននៃថ្ងៃនេះ ៖ | ____________________ |
| ឈ្មោះកុមារ ៖ | ____________________ |
| អាយុកុមារ ៖ | ____________________ |
| ឈ្មោះមាតាបិតា ឬអាណាព្យាបាល ៖ | ____________________ |
| ឈ្មោះអង្គការដែលពាក់ព័ន្ធ ៖ | ____________________ |

**ព័ត៌មានអំពីការព្រួយបារម្ភ/ករណីសង្ស័យ/ឧប្បទ្ទវហេតុ ៖**

*សូមបំពេញឱ្យបានច្រើនផ្នែកតាមដែលអាចធ្វើបាន ឱ្យបានលំអិត តាមដែលអ្នកអាចធ្វើបាន។*

១. សូមរៀបរាប់ពីអ្វីដែលបានកើតឡើង ៖ ពេលវេលា/កាលបរិច្ឆេទ/ឈ្មោះមនុស្សដែលពាក់ព័ន្ធ/ឥរិយាបថ ឬសញ្ញាដែលបានសង្កេតឃើញ/ព័ត៌មានលំអិតផ្សេងទៀត។

____________________
____________________
____________________
____________________
____________________
____________________
____________________

២. ព័ត៌មានលំអិតអំពីការសន្ទនា ដែលមានជាមួយកុមារ ៖

________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________
________________________________________________________________________________

៣. តើអ្នកបានទំនាក់ទំនងទៅកាន់អ្នកណាម្នាក់អំពីការព្រួយបារម្ភនេះទេ? បាន មិនបាន (*សូមគូសរង្វង់ជុំវិញចម្លើយតែមួយ)*

៤. បើដូច្នេះ តើអ្នកបានទាក់ទងអ្នកណាខ្លះ?

________________________________________________________________________________

________________________________________________________________________________

សូមចុះហត្ថលេខាលើរបាយការណ៍នេះ និងសរសេរឈ្មោះ និងមុខតំណែងរបស់អ្នកក្នុងអង្គការនេះ

ហត្ថលេខា ............................................................ កាលបរិច្ឆេទ ...........................................................

ឈ្មោះ ៖ ______________________________ មុខតំណែង ៖ ____________________________

---

សម្រាប់ប្រើដោយការិយាល័យ

*ឈ្មោះរបស់អ្នក ដែលបានទទួលរបាយការណ៍ឧប្បត្តិហេតុនេះ*_____________________________________

*កាលបរិច្ឆេទ ដែលបានទទួល* ________________________

*វិធានការ ដែលបានអនុវត្ត*____________________________________________________________
________________________________________________________________________________

________________________________________________________________________________

---

*ភ្ជាប់ឯកសារទាំងអស់*

*ហត្ថលេខា និងឈ្មោះរបស់បុគ្គល ដែលធ្វើការងារ ពាក់ព័ន្ធនឹងរបាយការណ៍នេះ*________________________

## ឧបសម្ព័ន្ធទី ៤ ៖ នីតិវិធីសម្រាប់រាយការណ៍

**អ្នកដែល អាចរាយការណ៍បាន**

បុគ្គលិក អ្នកស្ម័គ្រចិត្ត កុមារ ឬសហគមន៍

លើកឡើងពីការព្រួយបារម្ភ

**អ្វីដែលត្រូវរាយការណ៍**

- ការរំលោភបំពានកុមារ តាមរយៈការផ្ដល់ព័ត៌មានដោយកុមារ ភាគីទីបី និង/ឬការសង្កេតផ្ទាល់ **និង/ឬ**
- ការបំពាន ឬការអាចបំពានក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារ

**ពេលដែលត្រូវរាយការណ៍**

ឱ្យបានឆាប់តាមដែលអាចធ្វើបាន

**អ្នកដែលត្រូវរាយការណ៍ទៅ**

១. **ពិភាក្សាពីការព្រួយបារម្ភ**នានា ជាមួយនឹងមន្ត្រីការពារកុមាររបស់អង្គការសមត្ថភាពខ្ញុំ

២. បំពេញ**សន្លឹករាយការណ៍ពីឧប្បត្តិហេតុ**

មន្ត្រីការពារកុមាររបស់អង្គការសមត្ថភាពខ្ញុំនឹង ៖

៣. **កំណត់ពីហានិភ័យ**ចំពោះកុមារ (អាចកើតឡើងភ្លាម/អាចកើតមានឡើង) និងជន ប្រព្រឹត្ត ដែលទទួលរងការចោទប្រកាន់

៤. រៀបចំ**ផែនការសកម្មភាពបន្ទាន់**មួយ ដើម្បីធានាសុវត្ថិភាពរបស់កុមារ

**រាយការណ៍ពីក្ដីបារម្ភនេះ ទៅកាន់អាជ្ញាធរនគរបាលមូលដ្ឋាន** ជាពិសេស ប្រសិនបើកុមារកំពុងរងគ្រោះថ្នាក់ភ្លាមៗ ឬអាចរងគ្រោះថ្នាក់ [*សូមបញ្ចូលលេខទូរស័ព្ទ រួមទាំងលេខទូរស័ព្ទសម្រាប់ករណីបន្ទាន់* ]
អង្គភាពការពារកុមាររបស់រដ្ឋាភិបាល [*បញ្ចូលឈ្មោះអង្គភាពនេះ អាសយដ្ឋាន និងលេខទូរស័ព្ទ រួមទាំងខ្សែទូរស័ព្ទទាន់ហេតុការណ៍ ២៤ ម៉ោងនានា* ]

**ធានាឱ្យមានការបញ្ជូន និងការផ្ដល់ការគាំទ្រដល់កុមារ និងអ្នកដែលផ្ដល់ព័ត៌មាន**

**សុខភាសុខភាសុខភាព**
[*សូមបញ្ចូលលេខទូរស័ព្ទ រួមទាំងលេខទូរស័ព្ទ សម្រាប់ករណីបន្ទាន់* ]

**សេវាផ្ដល់ប្រឹក្សា**
[*សូមបញ្ចូលលេខទូរស័ព្ទ រួមទាំងលេខទូរស័ព្ទ សម្រាប់ករណីបន្ទាន់* ]

គ្រប់គ្រងផ្ទៃក្នុង

ពុំចាត់វិធានការបន្ត

## ឧបសម្ព័ន្ធទី ៥ ៖ ការគ្រប់គ្រងហានិភ័យ

នេះគឺជាឧទាហរណ៍អំពីឧបករណ៍ ដែលអង្គការមួយអាចប្រើប្រាស់ ដើម្បីវាយតម្លៃលើហានិភ័យចំពោះកុមារ ដែលបង្កឡើងដោយបុគ្គលិក និងអ្នកស្ម័គ្រចិត្ត។ សូមប្រើសំណួរខាងក្រោម ដើម្បីបំពេញតារាងម៉ាទ្រិចនេះ ៖

- **កំណត់** - តើកម្មវិធីនេះមានសកម្មភាពជាក់ស្តែងអ្វីខ្លះ ដែលនាំឱ្យមានហានិភ័យចំពោះកុមារ?
- **ហានិភ័យ** - តើអាចមានបញ្ហាអ្វីកើតមានឡើង?
- **លទ្ធភាព** - តើបញ្ហានេះទំនងជាកើតឡើងកម្រិតណា?
- **ផលប៉ះពាល់** - តើនឹងមានផលវិបាកអ្វីខ្លះចំពោះកុមារ?
- **វិធានការ** - កំណត់ពីវិធី ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ និងធនធាននានា ដែលចាំបាច់ ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ។

| កំណត់ពីហានិភ័យចំពោះកុមារ | ការវិភាគលើកត្តាហានិភ័យ | លទ្ធភាពដែលអាចកើតឡើង | | | ផលប៉ះពាល់ | វិធានការដែលត្រូវអនុវត្ត | ដោយអ្នកណា | ត្រឹមពេលណា |
|---|---|---|---|---|---|---|---|---|
| | | ខ្ពស់ | មធ្យម | ទាប | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

### គ្រប់គ្រងហានិភ័យ ដោយប្រើប្រាស់ចំណុចដែលស្នើខាងក្រោម ៖

- កំណត់វិធានការ
- កំណត់ធនធាន ដែលចាំបាច់ ដើម្បីកាត់បន្ថយហានិភ័យ
- ដាក់ឱ្យអនុវត្តនូវនីតិវិធី សម្រាប់ករណីនៅពេលដែលមានបញ្ហាកើតមានឡើង

### ពិនិត្យតាមដានលើការវាយតម្លៃលើហានិភ័យកម្មវិធី ដោយសួរសំណួរខាងក្រោម ៖

- តើហានិភ័យទាំងអស់ នៅតែកើតមានដែរឬទេ?
- តើហានិភ័យទាំងនេះត្រូវបានកាត់បន្ថយ ទប់ស្កាត់ និងគ្រប់គ្រង ដោយផែនការ ដែលមានស្រាប់ដែរឬទេ?
- តើមានហានិភ័យថ្មីៗដែរឬទេ?
- តើចាំបាច់ត្រូវមានវិធានការ និងធនធានអ្វីខ្លះ ដើម្បីកាត់បន្ថយ ដកចេញ និងទប់ស្កាត់ហានិភ័យថ្មីៗទាំងនេះ?

**ឧបសម្ព័ន្ធទី ៦ ៖ កិច្ចព្រមព្រៀងទទួលយកគោលនយោបាយស្តីពីកិច្ចការពារកុមារ**

# កិច្ចព្រមព្រៀងទទួលយក
# គោលនយោបាយស្តីពីកិច្ចការពារកុមារ

ខ្ញុំ ____________________ បានអានគោលនយោបាយស្តីពីកិច្ចការពារកុមាររបស់អង្គការសមត្ថភាពខ្ញុំ ហើយយល់ពេញលេញ និងទទួលយកខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។ ខ្ញុំយល់ព្រមអនុវត្តតាមពេញលេញ ចំពោះលក្ខខណ្ឌនានា នៅក្នុងឯកសារនេះ។

ហត្ថលេខា ៖ __________________________

កាលបរិច្ឆេទ ៖ __________________________

ឈ្មោះ ៖ ____________________________________